**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋានពន្ធដារ**

លេខ......៨៣០......អពដ

# សារលិខិតជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសខួបកំណើតគម្រប់ ៦៣ឆ្នាំ ឈានចូល ៦៤ឆ្នាំ
## ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤

ក្នុងឱកាសប្រកបដោយមហានក្ខត្តឫក្សប្រសើរថ្លៃថ្លា នៃពិធីបុណ្យខួបកំណើតគម្រប់ជន្មាយុ ៦៣ឆ្នាំ ឈានចូល ៦៤ឆ្នាំ របស់សម្តេច ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ នេះ ខ្ញុំបាទ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃអគ្គនាយកដ្ឋានពន្ធដារ សូមគោរពអនុញ្ញាតសម្តែងនូវសេចក្តីអំណរសាទរឥតឧបមា ចូលរួមជូននូវសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ ក្នុងមនោសញ្ចេតនាប្រកបដោយកតញ្ញូកតវេទិតាធម៌ដ៏ស្មោះស្ម័គ្របំផុត និងសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅ ជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ** ព្រមទាំងសូមសម្តែងនូវសេចក្តីកោតសរសើរយ៉ាងក្រៃលែង និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះស្មារតី និងសកម្មភាពស្នេហាជាតិប្រកបដោយគតិបណ្ឌិត បញ្ញាញាណដ៏ថ្លាថ្លៃ គំរូវីរភាពដ៏អង់អាចល្បាញល្បីដែល **សម្តេច**តែងតែយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធ ទេពកោសល្យដ៏ឧត្តុង្គឧត្តមប្រពៃ មកបម្រើផលប្រយោជន៍ជាតិ សាសនា ព្រះមហាក្សត្រ ដឹកនាំនាវាកម្ពុជារហូតទទួលបាននូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ បូរណភាពទឹកដី ស្ថិរភាពនយោបាយ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ។

ជាថ្មីម្តងទៀត ឆ្លៀតក្នុងឱកាសដ៏មហាជ័យមង្គល សិរីសួស្តី ប្រពៃថ្លៃថ្លា វិសេសវិសាលនេះផងដែរ ខ្ញុំបាទយើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា និងសូមលើកហត្ថប្រណម្យដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ជាពិសេស ទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំមមី ព្រះនាមគោរាគៈទេវី សូមតាមបីបាច់ថែរក្សា ប្រោះព្រំប្រទានសព្វសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ**សម្តេចតេជោនាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់របស់សម្តេច សូមប្រកបដោយសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លា ប្រាជ្ញាវាងវៃ ជន្មាយុយឺនយូរ ព្រមទាំងសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវអភិវន្ទនាការដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុត អំពីខ្ញុំបាទ ។

គោរពជូនពរនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**